ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * * * * *

ឆ្នាំទី ៦ លេខ ៤៤ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៤-១១-១៩៩៨ -ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៨ តែងតាំងឯកឧត្តម ឆាន់ សាផាន ជាអ្នកញ៉ា ១៥៥៩

២៧-១១-១៩៩៨ -ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧០ តែងតាំងលោក គិត ឡៀង ជាអ្នកញ៉ា ១៥៥៩

២៧-១១-១៩៩៨ -ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧១ តែងតាំងលោក លី ម៉ុនឡឿន ជាអ្នកញ៉ា ១៥៦០

៣០-១១-១៩៩៨ -ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ត្រូវបានបញ្ចប់តំណែងរាជរដ្ឋាភិបាល ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ និងតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាថ្មី ១៥៦០

II- រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៦-១១-១៩៩៨ -អនុក្រឹត្យលេខ ៧៣ អនក្រ.បក ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម ចំនួន ៥.៧០០ លានរៀល (ប្រាំពាន់ប្រាំពីររយលានរៀល) ទៅលើឥណទានថវិការបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ១៥៦៥

២៦-១១-១៩៩៨ -អនុក្រឹត្យលេខ ៧៤ អនក្រ.បក ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម ចំនួន ១.៣៥០ លានរៀល (មួយពាន់បីរយហាសិបលានរៀល) ទៅលើឥណទានថវិការបស់ក្រសួងមហាផ្ទៃ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ១៥៦៧

២៧-១១-១៩៩៨ -អនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពីការផ្ទេរវិមានរដ្ឋចំការមន របស់ទីស្តីការគណៈរដ្ឋមន្ត្រី អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នព្រឹទ្ធសភាជាតិ ស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងស្ថាប័ននៃក្រុមប្រឹក្សាធម្មនុញ្ញ ១៥៦៨

២៤-១១-១៩៩៨ -អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៦៩

២៥-១១-១៩៩៨ -អនុក្រឹត្យលេខ ២៣៥ អនក្រ.បក ស្តីពីការតម្លើងឋានន្តរស័ក្តិ និងតែងតាំងផ្លាស់ប្តូរមុខងារ ១៩៧០

២៥-១១-១៩៩៨ -អនុក្រឹត្យលេខ ២៣៦ អនុក្រ.បក ស្តីពីការកែសម្រួលឋានន្តរស័ក្តិ ១៩៧៣

២៥-១១-១៩៩៨ -អនុក្រឹត្យលេខ ២៣៧ អនក្រ.បក ស្តីពីការប្រគល់ឋានន្តរស័ក្តិ នាយទាហាន ១៩៧៤

III- ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៤៣ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ផ្លូកាមហ្គាមែន តំណាងដោយអ្នកស្រី សាត ទិមុល ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១៩៧៥

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៤៩ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហ៉ក់ស៊ីន អ៊ិនដា-ស្ទ្រីយ៍ ខូអិលធីឌី តំណាងដោយលោក WENG CHUN HSUAN សញ្ជាតិចិន(តៃវ៉ាន់) បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ នាំចេញ ១៩៧៧

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៥០ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន វីហ៊ើញ ហ្គាមិន ក្លឹតធីង ហ្វេកធឺរី អិលធីឌី តំណាងដោយលោក TAM CHU NG MING សញ្ជាតិ ចិន (ហុងកុង) បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១៩៧៨

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៥១ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន អ៊ីងដាហ្វូតវៀ អិលដាសស្រ្ទីល កូអិលធីឌី តំណាងដោយលោក យ៉ាំង ឈីងប៉ូ សញ្ជាតិកម្ពុជា បើកបង្កើតរោងចក្រផលិតស្បែកជើង ១៩៨០

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៥២ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហុងយ៉ូវ ស៊ីង (ខេមបូឌា) តំណាងដោយលោក HSIEH YINLI សញ្ជាតិ ចិន (តៃវ៉ាន់) រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១៩៨១

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៥៣ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន សម្បត្តិហ្គាមែន អិលធីឌី តំណាងដោយលោកស្រី គង់ សាខន សញ្ជាតិ កម្ពុជា បង្កើតរោងចក្រកាត់ដេរសំលៀក បំពាក់នាំចេញ ១៩៨៣

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៥៤ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនហ្វាក់ស៊ីនតិចអ៊ិលេដាក់ស្ទ្រីស ខេមបូឌា តំណាងដោយលោកCHAOYING MING សញ្ជាតិ ចិន (តៃវ៉ាន់) បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ នាំចេញ ១៩៨៥

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៥៥ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ខេមបូឌា អឹបពែរលេ អ៊ិនឌឹស្ទ្រី តំណាងដោយលោក ជុយ ទិនខឹង សញ្ជាតិ កម្ពុជា បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១៩៨៦

២៥-១១-១៩៩៨ -ប្រកាសលេខ ៦៥៦ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហ្វុងដា (កម្ពុជា) ហ្គាមិន តំណាងដោយលោក RUAN YONG QIANG សញ្ជាតិ ចិន បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១៩៨៧

២៦-១១-១៩៩៨ -ប្រកាសលេខ ៦៦៣ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន យូនីជីហ្វុល អឹបធីរ៉ល (ខេមបូឌា) ខូ អិលធីឌី តំណាងដោយលោក NGAN SHUN KWING BEN សញ្ជាតិ កាណាដា បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១៩៨៩

២-និស្ថិការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

២៥-១១-១៩៩៨ -ប្រកាសលេខ ២៦២/៩៨ ពម.ប្រក ទទួលស្គាល់ លោក TAKA TOSHI SHIOZOKI ជាប្រធាន ការិយាល័យនៃទីភ្នាក់ងារសារពត៌មានជប៉ុន NHK ប្រចាំនៅទីក្រុងភ្នំពេញ ១៩៩០

២៥-១១-១៩៩៨ -ប្រកាសលេខ ២៦៣/៩៨ ពម.ប្រក ទទួលស្គាល់លោក NGUYEN HUU HA ជាប្រធានការិយាល័យនៃទីភ្នាក់ងារសារពត៌មានវៀតណាម VNA ប្រចាំនៅទីក្រុងភ្នំពេញ ១៩៩២

៣-និស្ថិការរដ្ឋមន្ត្រី ក្រសួងបរិស្ថាន

សេចក្ដីសំរេច

២៧-១១-១៩៩៨ -សេចក្ដីសំរេចលេខ ១៩២៥ បស្ថ ស្ដីពីការបង្កើតក្រុមការងារត្រួត ពិនិត្យ និងកំណត់ព្រំប្រទល់ឧទ្យានជាតិ ព្រះសីហនុ “ រាម ” ១៩៩៣

៤–ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ប្រកាស

២៦-១១-១៩៩៨ -ប្រកាសលេខ ២៥៦ប្រក.វវគប ស្តីពីការបន្ថែមបេក្ខជនជាប់ការប្រឡង
បញ្ចប់សញ្ញាបត្រ ផ្នែកបុរាណវិទ្យាជំនាន់ទី៥ ឆ្នាំសិក្សា ឆ្នាំ ១៩៩៧-៩៨ ១៤៩៥

៥–រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

២៥-១១-១៩៩៨ -សេចក្តីសម្រេចលេខ ៦៧២ សសរ.អសរ.ក្រង ស្តីពីការបែងចែកនិស្សិត
ចំនួន ១០ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ១៤៩៧

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៨

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

ឯកឧត្តម ឆាន់ សាផាន

ជា

ឧកញ៉ា

រាជធានីភ្នំពេញ , ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៨

ព្រះហស្តលេខា

នរោត្តម សីហនុ

★ ★ ★

ព្រះរាជក្រឹត្យនស/រកត/១១៩៨/៧០

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក គិត ឆៀង

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧១

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក លី ប៊ុនធឿន

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

★ ★ ★

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមលទ្ធផលនៃការបោះឆ្នោត ស្ដីពីការជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៩៨
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមលទ្ធផលនៃការបោះឆ្នោតសំដែងការទុកចិត្តរបស់រដ្ឋសភាលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីចាត់តាំង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨

ត្រាស់បង្គាប់

មាត្រា ១ ._ ត្រូវបានបញ្ចប់តំណែងរាជរដ្ឋាភិបាលកម្ពុជា ដែលបានតែងតាំងដោយព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ហើយដែលបានកែសម្រួលដោយព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ដោយព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ និង ដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧។

មាត្រា ២ ._ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពក្រសួង និងរដ្ឋលេខាធិការដ្ឋានដូចតទៅ :

I- នាយករដ្ឋមន្ត្រី : សម្តេច ហ៊ុន សែន

II- ឧបនាយករដ្ឋមន្ត្រី :

-ឯកឧត្តម ស ខេង និង ឯកឧត្តម តុល ឡោះ

III- ទេសរដ្ឋមន្ត្រី :

-ឯកឧត្តម ទៀ បាញ់ ឯកឧត្តម លី ធ្លាយស្រេង

-ឯកឧត្តម គាត ឈន់ ឯកឧត្តម ឈឹម សៀកឡេង

-ឯកឧត្តម សុខ អាន ឯកឧត្តម ហុង ស៊ុនហួត

-ឯកឧត្តម ហោ ណាំហុង ឯកឧត្តម យូ ហុកគ្រី

IV- អំពីក្រសួង :

១-ទីស្តីការគណៈរដ្ឋមន្ត្រី :

-រដ្ឋមន្ត្រី	:	ឯកឧត្តម សុខ អាន
-រដ្ឋលេខាធិការ	:	ឯកឧត្តម ស៊ុំ ម៉ានិត
	:	ឯកឧត្តម ជា សោភ័ណ

២-ក្រសួង ការពារជាតិ :

-សហរដ្ឋមន្ត្រី : ឯកឧត្តម ទៀ បាញ់ និង អ្នកឧង្គម្ចាស់ ស៊ីសុវត្ថិ សិរីវុឌ្ឍ

-រដ្ឋលេខាធិការ	:	ឯកឧត្តម ចាយ សាំងយុន
	:	ឯកឧត្តម ប៉ោ ម៉ុនស្រ៊ី

៣-ក្រសួង មហាផ្ទៃ :

-សហរដ្ឋមន្ត្រី	:	ឯកឧត្តម ស ខេង និង ឯកឧត្តម យូ ហុកគ្រី
-រដ្ឋលេខាធិការ	:	ឯកឧត្តម ឯម សំអាន
	:	ឯកឧត្តម គៀង វ៉ាង
	:	ឯកឧត្តម ប្រ៊ុំ សុខា
	:	ឯកឧត្តម ចាន់ ស៊ីណា

៤-ក្រសួងទំនាក់ទំនងសភា និង អធិការកិច្ច :

-រដ្ឋមន្ត្រី : ឯកឧត្តម ឃុន ហាំង
-រដ្ឋលេខាធិការ : ឯកឧត្តម ខួន ម៉េងហ៊ាន
: ឯកឧត្តម ហុង ថែម

៥-ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ :

-រដ្ឋមន្ត្រី : ឯកឧត្តម ហោ ណាំហុង
-រដ្ឋលេខាធិការ : ឯកឧត្តម អ៊ុន គឹមអន
: ឯកឧត្តម ឆឹង ចំរើន

៦-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ :

-រដ្ឋមន្ត្រី : ឯកឧត្តម គាត ឈន់
-រដ្ឋលេខាធិការ : ឯកឧត្តម អ៊ុក រ៉ាប៊ុន
: ឯកឧត្តម គង់ វិបុល

៧-ក្រសួងពត៌មាន :

-រដ្ឋមន្ត្រី : ឯកឧត្តម លី ឡាយស្រេង
-រដ្ឋលេខាធិការ : ឯកឧត្តម ខៀវ កាញារីទ្ធ

៨-ក្រសួងសុខាភិបាល :

-រដ្ឋមន្ត្រី : ឯកឧត្តម ហុង ស៊ុនហួត
-រដ្ឋលេខាធិការ : ឯកឧត្តម អ៊ឹង តីរុន
: ឯកឧត្តម ម៉ម ប៊ុនហេង

៩-ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល :

-រដ្ឋមន្ត្រី : ឯកឧត្តម ស៊ុយ សែម
-រដ្ឋលេខាធិការ : ឯកឧត្តម អ៊ិត ប្រាំង
: ឯកឧត្តម ញៀម ប៊ុនជិន

១០-ក្រសួងផែនការ :

-រដ្ឋមន្ត្រី : ឯកឧត្តម ឆាយ ថន
-រដ្ឋលេខាធិការ : ឯកឧត្តម អ៊ូ ឱហាត
: ឯកឧត្តម ឡាយ ព្រហស្ព

១១-ក្រសួងពាណិជ្ជកម្ម :

-រដ្ឋមន្ត្រី : ឯកឧត្តម ចម ប្រសិទ្ធ
-រដ្ឋលេខាធិការ : ឯកឧត្តម ប៉ែន ស៊ីម៉ន
: ឯកឧត្តម ខែក រ៉ាវី

១២-ក្រសួងអប់រំ យុវជន និង កីឡា :

-រដ្ឋមន្ត្រី : ឯកឧត្តម តុល ឡោះ

-រដ្ឋលេខាធិការ : ឯកឧត្តម ម៉ុក ចុន

: ឯកឧត្តម អ៊ឹម សិទ្ធី

១៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ :

-រដ្ឋមន្ត្រី : ឯកឧត្តម ឈា សុង

-រដ្ឋលេខាធិការ : ឯកឧត្តម ចន់ តុងអ៊ីវ

: ឯកឧត្តម ម៉ៅ សុំអឿន

១៤-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ :

-រដ្ឋមន្ត្រី : សម្តេចព្រះរាជ នរោត្តម បុប្ផាទេវី

-រដ្ឋលេខាធិការ : អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ

: ឯកឧត្តម ម៉ឺន យ៉េត

១៥-ក្រសួងបរិស្ថាន :

-រដ្ឋមន្ត្រី : ឯកឧត្តម ម៉ុក ម៉ារ៉េត

-រដ្ឋលេខាធិការ : ឯកឧត្តម ឆាន់ សាផាន់

: ឯកឧត្តម តូ ហ្គារី

១៦-ក្រសួងអភិវឌ្ឍន៍ជនបទ :

-រដ្ឋមន្ត្រី : ឯកឧត្តម ឈឹម សៀកឡេង

-រដ្ឋលេខាធិការ : ឯកឧត្តម លី ធុច

: ឯកឧត្តម យឹម ឆៃលី

១៧-ក្រសួងសង្គមកិច្ចការងារ- បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា :

-រដ្ឋមន្ត្រី : ឯកឧត្តម អ៊ិត សំហេង

-រដ្ឋលេខាធិការ : ឯកឧត្តម នឹម ថូត

: ឯកឧត្តមជំទាវ ប្រាក់ ចន្ថា

១៨-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ :

-រដ្ឋមន្ត្រី : ឯកឧត្តម សូ ឃុន

-រដ្ឋលេខាធិការ : ឯកឧត្តម ផាន់ គិន

: ឯកឧត្តម ឡាំ គូអាន

១៩-ក្រសួងធម្មការ និង កិច្ចការសាសនា :

-រដ្ឋមន្ត្រី : ឯកឧត្តម ជា សាវឿន

–រដ្ឋលេខាធិការ : ឯកឧត្តម ស្រី ទណ្ឌផ្ទង់

: ឯកឧត្តម ឈន អៀម

២០–ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន :

–រដ្ឋមន្ត្រី : លោកជំទាវ មូរ សុខហួរ

–រដ្ឋលេខាធិការ : លោកជំទាវ អ៊ឹង កន្ថាផាវី

: លោកជំទាវ យូ អយ

២១–ក្រសួងសាធារណការ និង ដឹកជញ្ជូន :

–រដ្ឋមន្ត្រី : ឯកឧត្តម ឃី តាំងលីម

–រដ្ឋលេខាធិការ : ឯកឧត្តម អះម៉ាត់ យ៉ះយ៉ា

: ឯកឧត្តម ទ្រាំ អ៊ីវតឹក

២២–ក្រសួងយុត្តិធម៌ :

–រដ្ឋមន្ត្រី : ឯកឧត្តម អ៊ុក វិថុន

–រដ្ឋលេខាធិការ : ឯកឧត្តម ស៊ុយ នូ

: លោកជំទាវ លី វួចឡេង

២៣–ក្រសួងទេសចរណ៍ :

–រដ្ឋមន្ត្រី : ឯកឧត្តម វ៉េង សេរីវុឌ្ឍ

–រដ្ឋលេខាធិការ : ឯកឧត្តម នុត និនឡឿន

: ឯកឧត្តម ថោង ខុន

២៤–ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ :

–រដ្ឋមន្ត្រី : ឯកឧត្តម អ៊ឹម ឈុនលឹម

–រដ្ឋលេខាធិការ : ឯកឧត្តម ធី យ៉ាវ

: ឯកឧត្តម នូ សាំងខន

២៥–ក្រសួងធនធានទឹក និង ឧតុនិយម :

–រដ្ឋមន្ត្រី : ឯកឧត្តម លឹម គានហោ

–រដ្ឋលេខាធិការ : ឯកឧត្តម អ៊ី គីហ៊ាង

: ឯកឧត្តម ទៅ ពិន

V–អំពីរដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី :

១–រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ :

–រដ្ឋលេខាធិការ : ឯកឧត្តម ពេជ្រ ប៊ុនធិន

២-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល :

-រដ្ឋលេខាធិការ : ឯកឧត្តម ម៉ុក សំឯល

មាត្រា ៣ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨

ព្រះហស្ថលេខា

នរោត្តម សីហនុ

★ ★ ★

II- រាជរដ្ឋាភិបាល

អនុក្រឹត្យ

អនុក្រឹត្យលេខ ៧៣ អនក្រ.បក

ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម

ចំនួន ៥ ៧០០ លានរៀល (ប្រាំពាន់ ប្រាំពីររយលានរៀល)

នៅលើឥណទានថវិការបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

★ ★ ★

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងនាយករដ្ឋមន្ត្រី

- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១០៩៦/១៨ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១ នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដែលបានប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ១៩៩៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ១៩៩៨ របស់រាជរដ្ឋាភិបាល ស្ដីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៥ ប្រ.ក.សហវ.ថ ចុះថ្ងៃទី២៧ ខែ មករា ឆ្នាំ ១៩៩៨ ស្ដីពីការបែងចែកឥណទានផ្ទៃក្នុងជំពូកតាមប្រការ កថាខណ្ឌ វាក្យខណ្ឌ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ ._ ដោយអនុលោមទៅតាមមាត្រា ៥៦ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតអោយផ្ដល់បន្ថែមឥណទានថវិកាចំនួន ៥.៧០០លានរៀល (ប្រាំពាន់ ប្រាំពីររយលានរៀល) ទៅលើសៀវភៅរបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

មាត្រា ២ ._ ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា១ ខាងលើត្រូវបានផ្ដល់បន្ថែមនៅជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈនិងផ្គត់ផ្គង់តូចតាច) ចំនួន ៥.៧០០លានរៀល ដើម្បីចំណាយទូទាត់ប្រេងឥន្ធនៈឆ្នាំ ១៩៩៨ សងអោយក្រុមហ៊ុន សូ គីមិច ។

មាត្រា ៣ ._ ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៤ . ឥណទានថវិកាបន្ថែមនេះ ត្រូវរដ្ឋសភាពិនិត្យអនុម័តជាបន្ទាន់ភ្ជាប់ក្នុងច្បាប់ហិរញ្ញវត្ថុបន្ថែមមួយពេលក្រោយពីសម័យប្រជុំនេះត្រូវបានចប់សព្វគ្រប់ ។

មាត្រា ៥ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★

អនុក្រឹត្យលេខ ៧៨ អនក្រ.បក
ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម ចំនួន ១ ៣៥០ លានរៀល (មួយពាន់ បីរយហាសិបលានរៀល) នៅលើឥណទានថវិកា របស់ ក្រសួងមហាផ្ទៃ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

★ ★ ★

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១០៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១ នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ១៩៩៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៥ ប្រ.ក.សហវ.ថ ចុះថ្ងៃទី២៧ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកឥណទានថ្លៃក្នុងជំពូកតាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ ._ ដោយអនុលោមទៅតាមមាត្រា ៥៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតអោយផ្តល់បន្ថែមឥណទានថវិកាចំនួន ១ ៣៥០ លានរៀល (មួយពាន់បីរយហាសិបលានរៀល) ទៅលើគម្រោងថវិការបស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

មាត្រា ២ ._ ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា១ ខាងលើត្រូវបានផ្តល់បន្ថែមនៅជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈនិងផ្គត់ផ្គង់ទូទៅ) ចំនួន ១ ៣៥០ លានរៀល របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ដើម្បីធានាចំណាយទូទាត់ប្រេងឥន្ធនៈ ឆ្នាំ១៩៩៨ សងអោយក្រុមហ៊ុន សូ គីមិច ។

មាត្រា ៣ ._ ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៤ ._ ឥណទានថវិកាបន្ថែមនេះ ត្រូវរដ្ឋសភាពិនិត្យអនុម័តជាបន្ទាន់ក្នុងច្បាប់ហិរញ្ញវត្ថុបន្ថែមមួយ ហើយចំណាយពិសេសនេះត្រូវបានចាត់ទុកត្រឹមត្រូវ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ៖ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★

អនុក្រឹត្យលេខ ៧៥ អនក្រ.បក

ស្តីពីការផ្ទេរវិមានរដ្ឋចំការមនរបស់ទីស្តីការគណៈរដ្ឋមន្ត្រីអោយ

ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នព្រឹទ្ធសភាជាតិ

ស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងស្ថាប័ននៃក្រុមប្រឹក្សាធម្មនុញ្ញ

★ ★ ★ ★

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមសំណូមពរចាំបាច់

សំរេច

មាត្រា ១ ._ វិមានរដ្ឋចំការមនរបស់ទីស្តីការគណៈរដ្ឋមន្ត្រី រួមទាំងចលនវត្ថុ និងអចលនវត្ថុ ត្រូវបានផ្ទេរអោយស្ថិតក្រោមការគ្រប់គ្រងរបស់ ៖

- ស្ថាប័នព្រឹទ្ធសភាជាតិនូវអាគារលើរឿង អាគារក្រោម និងអាគារកញ្ចក់មទឹងថ្មើជាប់ផ្លូវធំចំនួនប្រាំមួយខ្នង ។
- ស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនូវអាគារជាប់រោងបញ្ចាំង ភាពយន្តចំនួនមួយខ្នង ។
- ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ នូវអាគារសចំនួន មួយខ្នង ។

មាត្រា ២ ._ ក្របខ័ណ្ឌមន្ត្រីរាជការដែលបំរើការនៅវិមានរដ្ឋចំការមន នឹងធ្វើការពិនិត្យតាមសភាពជាក់ស្តែង ។

មាត្រា ៣ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានស្ថាប័នព្រឹទ្ធសភាជាតិ ស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង- ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★

អនុក្រឹត្យលេខ ២៣៤ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

★ ★ ★

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៧/៨៣ ចុះថ្ងៃទី២៩ ខែ តុលា ឆ្នាំ ១៩៩៧ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៧/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៧ និងព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែប្រែសមាសភាពថ្មី របស់រាជរដ្ឋាភិបាលកម្ពុជា

យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១.- តែងតាំងលោកស្រី **ម៉ាសសាឯម ដានី** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក ជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងនូវែលសេឡង់ ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នៃស្ថាប័នពាក់ព័ន្ធទាំងឡាយ និងលោកស្រី **ម៉ាសសាឯម ដានី** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

★ ★ ★

អនុក្រឹត្យលេខ ២៣៥ អនក្រ.តត
ស្តីពីការតម្លើងឋានន្តរសក្តិ និងតែងតាំងផ្លាស់ប្តូរមុខងារ

★ ★ ★

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាព នៃរាជរដ្ឋាភិបាលកម្ពុជា
- បើតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរសក្តិ និង តែងតាំងផ្លាស់ប្តូរមុខងារ នាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទដែលមានរាយនាមដូចខាងក្រោម ៖

ក-តម្លើងឋានន្តរសក្តិជា វរសេនីយ៍ឯក

១-លោកវរសេនីយ៍ទោ **អន កំសត់** អត្តលេខ ០០០៦៣៦ លេខាធិការរងក្រុមការអគ្គសេនាធិការ បច្ចុប្បន្នជា នាយរងខុទ្ទកាល័យ អគ្គសេនាធិការ

២-លោកវរសេនីយ៍ទោ **កែន តារ៉ា** អត្តលេខ ០០០៦៧៥ នាយផ្នែកផែនការ ការិយាល័យទី៥ បច្ចុប្បន្នជា នាយរងការិយាល័យទី៥ អគ្គសេនាធិការ

៣-លោកវរសេនីយ៍ទោ **មាស សក្តិ** អត្តលេខ ០០០៧៥៧ នាយផ្នែកបុគ្គលិក កងអន្តរាគមន៍ បច្ចុប្បន្នជា នាយសេនាធិការរង កងអន្តរាគមន៍ អគ្គសេនាធិការ

៤-លោកវរសេនីយ៍ទោ **ឆេ ខា** អត្តលេខ ០០០៩៥៨ មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ បច្ចុប្បន្នជា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ យោធភូមិភាគទី៣

៥-លោកវរសេនីយ៍ទោ **កាន់ ណាំង** អត្តលេខ ០០០៩៥៩ មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងកោះកុង បច្ចុប្បន្នជា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកោះកុង យោធភូមិភាគទី៣

៦-លោកវរសេនីយ៍ទោ **ឈួរ ចាន់ឡឿន** អត្តលេខ ០០០៨៦៤ មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង បច្ចុប្បន្នជា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង យោធភូមិភាគពិសេស

៧-លោកវរសេនីយ៍ទោ **ងាញ់ ឡេង** អត្តលេខ ០០១០២៨ មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងបាត់ដំបង បច្ចុប្បន្នជា មេបញ្ជាការរងកងពលតូចលេខ ១២

៨-លោកវរសេនីយ៍ទោ **ទេ ជា** អត្តលេខ ០០០៥៧១ នាយការិយាល័យសព្វាវុធ បច្ចុប្បន្នជា នាយករង នាយកដ្ឋានសម្ភារៈបច្ចេកទេស ក្រសួងការពារជាតិ

៩-លោកវរសេនីយ៍ទោ **ម៉ម យឿន** អត្តលេខ ០០០៧២៥ នាយករងសាលានាយទាហាន អគ្គសេនាធិការ បច្ចុប្បន្នជា នាយកសាលានាយទាហាន អគ្គសេនាធិការ

១០-លោកវរសេនីយ៍ទោ **ទ៉ាន់ ម៉ុនលាង** អត្តលេខ ០០១១០៤ នាយការិយាល័យទី២ បញ្ជាការដ្ឋានកងនាវាចរ បច្ចុប្បន្នជា នាយសេនាធិការរង បញ្ជាការដ្ឋានកងនាវាចរ

១១-លោកវរសេនីយ៍ទោ **ស្រួង សារី** អត្តលេខ ០០១១០៥ នាយការិយាល័យទី៣ បញ្ជាការដ្ឋានកងនាវាចរ បច្ចុប្បន្នជា នាយសេនាធិការរង បញ្ជាការដ្ឋានកងនាវាចរ

១២-លោកវរសេនីយទោ លុយ សម្បត្តិ អត្តលេខ ០០១០៧១ នាយសេនាធិការរង កងពលធំលេខ១២ យោធភូមិភាគទី៥ បច្ចុប្បន្នជា មេបញ្ជាការរង កងពលធំលេខ១២ យោធភូមិភាគទី៥

១៣-លោកវរសេនីយទោ សុខ វិណា អត្តលេខ ០០១១៩៥ នាយការិយាល័យផែនការសរុប ទីចាត់ការការងារគលយុទ្ធ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា មេបញ្ជាការរងកងពលធំលេខ ១២

១៤-លោកវរសេនីយទោ ខេត ម៉ុន អត្តលេខ ០០១០៤៥ មេបញ្ជាការវរសេនាធំលេខ៤៣ កងពលធំលេខ៤ យោធភូមិភាគទី២ បច្ចុប្បន្នជា នាយសេនាធិការ កងពលធំលេខ ៤ យោធភូមិភាគទី ២

ខ-តែងតាំង និងផ្លាស់ប្តូរមុខងារ

១-លោកវរសេនីយឯក ឈឹម សំអាង អត្តលេខ ០០០៣៥៤ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង កំពង់ឆ្នាំង បច្ចុប្បន្នជា នាយសេនាធិការរង យោធពលភូមិភាគពិសេស

២-លោកវរសេនីយឯក យ៉ោក ទណ្ណាលុច អត្តលេខ ០០០៣៨៩ មេបញ្ជាការរងកងពលធំលេខ ២ បច្ចុប្បន្នជា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ យោធភូមិភាគទី៤

៣-លោកវរសេនីយឯក ធូ ជា អត្តលេខ ០០០៣១៥ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកោះកុង បច្ចុប្បន្នជា នាយទាហានរង់ចាំការងារ បញ្ជាការដ្ឋានវជ្ជកាយ អគ្គសេនាធិការ

៤-លោកវរសេនីយឯក ឡុង ខេង អត្តលេខ ០០០៤២៩ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី ៣

៥-លោកវរសេនីយឯក ឈាន ឆន អត្តលេខ ០០១០០៤ មេបញ្ជាការរង បញ្ជាការដ្ឋានទ័ពព្រៃ បច្ចុប្បន្នជា មេបញ្ជាការកងពលតូចទ័ពព្រៃទី១ បញ្ជាការដ្ឋានទ័ពព្រៃ

៦-លោកវរសេនីយឯក សេង ចាន់ធី អត្តលេខ ០០០៥៩០ នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ ក្រសួងការពារជាតិ បច្ចុប្បន្នជា នាយរងខុទ្ទកាល័យ អគ្គសេនាធិការ

៧-លោកវរសេនីយឯក ជាត ចន្នា អត្តលេខ ០០០៣៣៦ នាយកគណៈនាយទាហានអគ្គសេនាធិការ បច្ចុប្បន្នជា នាយរងទីចាត់ការហ្វឹកហ្វឺន អគ្គសេនាធិការ

៨-លោកវរសេនីយឯក សោម សាគួន អត្តលេខ ០០០៧៧១ មេបញ្ជាការកងពលតូចទ័ពព្រៃទី១ បច្ចុប្បន្នជា មេបញ្ជាការរងកងពលធំលេខ៥ អគ្គសេនាធិការ

៩-លោកវរសេនីយឯក សៅ កុសល អត្តលេខ ០០០៤០៦ នាយសេនាធិការ កងពលធំលេខ ៤ យោធភូមិភាគទី២ បច្ចុប្បន្នជា មេបញ្ជាការរងកងពលធំលេខ៤ យោធភូមិភាគទី២

១០-លោកវរសេនីយឯក ម៉ែន សារឿន អត្តលេខ ០០០៤២២ មេបញ្ជាការរងកងពលធំលេខ១២ យោធភូមិភាគទី៥ បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី៥

១១-លោកវរសេនីយឯក ម៉ៅ សាខុន អត្តលេខ ០០០៣១៩ មេបញ្ជាការរងកងពលធំលេខ ១២ យោធភូមិភាគទី៥ បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី២

មាត្រា ២ .- សហការីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហការីរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្តន៍ អនុក្រឹត្យនេះដែលចូលជាធរមានច្បាប់ គិតពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹុង ហួត ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ២៣៦ អនក្រ.តត
ស្ដីពីការ កែសំរួលឋាននន្ដរស័ក្តិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ សហការីរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ .- ត្រូវបានកែសំរួលឋាននន្ដរស័ក្តិ ថ្នាក់ វរសេនីយឯក នាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទដែលមានរាយនាមដូចខាងក្រោម ៖

១-លោក ផាន់ និន្ទ មេបញ្ជាការរងទទួលបន្ទុកយន្តហោះស្លាប់ កងអាកាសចរ

២-លោក ម៉ាញ យ៉ារិន មេបញ្ជាការរង ទទួលបន្ទុកប្រតិបត្តិការហ្វឹកហ្វឺន កងអាកាសចរ

៣-លោក សូ ណារ៉ា មេបញ្ជាការរង ទទួលបន្ទុកបច្ចេកទេស កងអាកាសចរ

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្តន៍ អនុក្រឹត្យនេះដែលចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

★ ★ ★

អនុក្រឹត្យលេខ ២៣៧ អនក្រ.តត

ស្តីពីការប្រគល់ឋានន្តរសក្តិ នាយទាហាន

★ ★ ★

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាព នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១.- ត្រូវបានប្រគល់ឋានន្តរសក្តិ នាយទាហាន ថ្នាក់វរសេនីយឯក ក្នុងកងយោធពលខេមរភូមិន្ទដែលមានរាយនាមដូចខាងក្រោម ៖

១-លោក **ឌូ គ្រួយ** នាយសេនាធិការរង យោធភូមិភាគទី ៤

២-លោក **ទី ម្រូ** នាយសេនាធិការរង យោធភូមិភាគទី ១

៣-លោក **នួន ឡឿន** មេបញ្ជាការរង កងពលធំលេខ ២៣

៤-លោក ទ្រាំ ឈន មេបញ្ជាការរង កងពលធំលេខ ២៣

៥-លោក លី ស៊ុន មេបញ្ជាការរង កងពលធំលេខ ២៣

៦-លោក សៀង ឆាំ មេបញ្ជាការរង កងពលធំលេខ ២៣

៧-លោក ពិន ពីម មេបញ្ជាការរង កងពលធំលេខ ២៣

៨-លោក ឌុំ ជឿន មេបញ្ជាការរង កងពលធំលេខ ២៤

៩-លោក ឌូ ជួន មេបញ្ជាការរង កងពលធំលេខ ២៤

១០-លោក ស្រី ធី មេបញ្ជាការរង កងពលធំលេខ ២៤

១១-លោក ស៊ីម សៅ មេបញ្ជាការរង កងពលធំលេខ ២៤

១២-លោក ឃុន ស៊ុន មេបញ្ជាការរង កងពលធំលេខ ២៤

១៣-លោក សេង សាន នាយសេនាធិការ កងពលធំលេខ ២៤

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្តន៍ អនុក្រឹត្យនេះដែលចូលជាធរមានច្បាប់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

III- ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

ប្រកាសលេខ ៦៤៣ ឧករ.ប្រក

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទ សម្តេច នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញលិខិតលេខ ៩៦២/៩៦ គ.វ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៥០៩៩ សអ.សរ ចុះថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ ១៩៩៦ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយសាងសង់អគារកាត់ដេរ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន គ្លូបាល់ ហ្គាមែន ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៨

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន គ្លូបាល់ ហ្គាមែន (GLOBAL GARMENT Co,LTD) តំណាងដោយអ្នកស្រី គាត វិបុលា សញ្ជាតិ កម្ពុជា អាយុ ៣៣ ឆ្នាំ អាសយដ្ឋានផ្ទះលេខ ៤DE1, ផ្លូវលេខ ២៣០ សង្កាត់ ផ្សារដើមគរ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៦៩២៥៤ ភ.ព ចុះថ្ងៃទី ២៨-៥-១៩៩១ បង្កើត " រោងចក្រកាត់ដេរ និងចាក់សំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ គ្លូបាល់ " មានទីតាំងស្ថិតនៅ សង្កាត់ ទួលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់ ការរៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយះពេល ០៣ ខែ ដោយរាប់បញ្ចូលទាំងរយះពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " កាត់ដេរ និង ចាក់សំលៀកបំពាក់ " ទៅតាមគំរូបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេចត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន គ្លូបាល់ ហ្គាមែន ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ិត ប្រាំង

★ ★ ★

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

ប្រកាសលេខ ៦៤៩ ឧក.ប្រក

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

★ ★ ★

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៥៥២/៩៨ គ.វ.ក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៣២៣២ ធគ.ស ចុះថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយបើកទីតាំងរោងចក្រកាត់ដេរ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន យ៉ាស៊ីន អ៊ីនដាស្ទ្រីយ៍ ខូអិលធីឌី ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន យ៉ាស៊ីន អ៊ីនដាស្ទ្រីយ៍ ខូអិលធីឌី (YASHIN INDUSTRIES Co,LTD) តំណាងដោយលោក WENG CHUN HSUAN សញ្ជាតិ ចិន (តៃវ៉ាន់) ភេទ ប្រុស អាយុ ៤១ឆ្នាំ អាសយដ្ឋាន 21FNo 1 POO SANG RD YUAN HO CITY TAIPEI, TAIWAN R.O.C កាន់លិខិតឆ្លងដែនលេខ M 14354506 ចុះថ្ងៃទី ១៣-៨-១៩៩៧ បង្កើត " រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ យ៉ាស៊ីន អ៊ីនដាស្ទ្រីយ៍ " មានទីតាំងស្ថិតនៅ ភូមិព្រៃពពេល សង្កាត់ ស្ទឹងមានជ័យ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់ ការរៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានដាក់ជូនមុនទៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ០៣ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " កាត់ ដេរ សំលៀកបំពាក់ " ទៅតាមគំរូបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលរបស់ក្រុមហ៊ុនត្រូវតែមានវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន កាំស៊ីន អ៊ិនដាស្ទ្រីយ៍ ខូអិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាព អនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ិត ប្រាំង

★ ★ ★

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ប្រកាសលេខ ៦៥០ ឧក.ប្រក

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

★ ★ ★

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៦៣២/៩៧ ក.អ.ក/ត.រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ១៩៩៧ របស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វីលីញ ហ្គាមិន ក្និតធីង ហ្វេកធឺរី អិលធីឌី ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ១៩៩៩

សម្រេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន វីលីញ ហ្គាមិន ក្និតធីង ហ្វេកធឺរី អិលធីឌី(WILLING GARMENT KNITTING FACTORY LTD) តំណាងដោយលោក TAM CHUNG MING សញ្ជាតិ ចិន (ហុងកុង) ភេទប្រុស អាយុ ៥២ឆ្នាំ អាសយដ្ឋាន No B15, FLAMINGO GARDEN , DD 226 LOT831 OFF,FEINGO SHAN ROAD, KOWLOON, HONGKONG, កាន់លិខិតឆ្លងដែន លេខ E 825375 (0) ចុះថ្ងៃទី ០៣-៣-១៩៩៧ បង្កើត " រោងចក្រចាក់សំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា " វីលីញ ហ្គាមិន ក្និតធីង ហ្វេកធឺរី " មានទីតាំងស្ថិតនៅ ជីឡូម៉ែត្រលេខ ៦៥ ផ្លូវជាតិលេខ ២ សង្កាត់ ចាក់អង្រែក្រោម ខណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង តំរូវលក្ខណៈបច្ចេកទេសបង្កើតរោងចក្រ ចាក់សំលៀកបំពាក់ ដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " ចាក់សំលៀកបំពាក់ " ទៅតាមគំរូបានតំកល់ ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលរបស់រោងចក្រក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

